# ព្រះសម្មាសម្ពុទ្ធ

ព្រះពុទ្ធគឺជាសាស្តានៃព្រះពុទ្ធសាសនាដែលមានព្រះនាមដើមជាសិទ្ធត្ថគោតម។ សិទ្ធត្ថកុមារជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ និងព្រះនាងសិរិមហាមាយា។ ព្រះអង្គជាពូជសាក្យវង្សដែលមានព្រះរាជនិវេសដ្ឋាន នៅក្រុងកបិលវត្ថុនៃដែនសក្កជនបទជាប្រទេសចំណុះឲ្យដែនកោសល មានព្រះបាទបសេនទិគ្រងរាជ្យមានក្រុងសាវត្ថីជារាជធានី។ ព្រះសិទ្ធត្ថកុមារប្រសូតិក្នុងឧទ្យានលុម្ពិនី(សព្វថ្ងៃស្ថិតនៅប្រទេស នេប៉ាល់)ក្នុងរវាងព្រះរាជនិវត្តន៍ទៅកាន់មាតុប្រទេសនៃព្រះនាងសិរិមហាមាយា ព្រះពុទ្ធមាតា។ ព្រះអង្គរៀបអភិសេកជាមួយ ព្រះនាងយសោធរា(ពិម្ពា)រាជបុត្រីនៃព្រះបាទសុប្បពុទ្ធ និងព្រះនាងបមិត្តាព្រះរាជកនិដ្ឋាពៅនៃព្រះបាទសុទ្ធោទនៈផ្ទាល់កាល ព្រះជន្មាយុ១៦ព្រះវស្សា ហើយតមកព្រះជន្មាយុបាន២៩ព្រះវស្សា ព្រះនាងពិម្ពាទេវីក៏បានប្រសូតិព្រះរាហុលនាថ្ងៃពេញបូរមីព្រះ ចន្ទ្រពេញវង់ដែលស្របពេលជាមួយនោះព្រះសិទ្ធត្ថរាជកុមារក៏បានចេញសាង ព្រះផ្នួសធ្វើទុក្ករកិរិយា៦ព្រះវស្សា ហើយក្រោយ មកបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្រោមគល់ពោធិព្រឹក្សនាមាត់ស្ទឹងនេរញ្ជរា  (ពុទ្ធគយាសព្វថ្ងៃ)។ ព្រះធម៌ដែលព្រះ អង្គបានត្រាស់ដឹងនោះហើយបានពុទ្ធាភិសេកព្រះអង្គឲ្យបានជាអង្គព្រះសម្មាសម្ពុទ្ធ ឬព្រះពុទ្ធនេះឯង។

សូមអស់លោកអ្នកអនុមោទនា!